# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៥៨ ព.ណ. ភស.ប. ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីសម្រាប់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ/បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក
- យោងតាមការងារចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និង សំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និង ការនាំចូល និងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅៈ

១- កំណត់នីតិវិធីលម្អិតសម្រាប់ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និង ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

២- កំណត់វិសាលភាពនៃ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និង ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

៣- កំណត់គោលការណ៍ក្នុងការបែងចែកទំនិញពាក់ម៉ាកផ្តាច់មុខនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៤- កំណត់នីតិវិធីដោះស្រាយវិវាទស្តីពី សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

៥- ចូលរួមចំណែកក្នុងការទប់ស្កាត់អំពើគេចពន្ធ ប្រមូលកម្រៃសេវាសាធារណៈ និងចំណូលពន្ធជូនរដ្ឋតាមបទប្បញ្ញត្តិជាធរមាន ។

**ប្រការ ៣.- វិសាលភាព**

១- ប្រកាសនេះ មានវិសាលភាពអនុវត្តលើ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ សម្រាប់ទំនិញដែលបានចុះបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានកំណត់ក្នុងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ។

២- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខគ្របដណ្តប់តែទៅលើទំនិញសុទ្ធនិងថ្មី ដែលមិនទាន់បានដាក់លក់ជាលើកដំបូងក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

១- "ការប្រគល់សិទ្ធិផ្តាច់មុខ" គឺជាការចេញលិខិតប្រគល់សិទ្ធិផ្តាច់មុខដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជូនទៅអ្នកទទួលសិទ្ធិដែលជានីតិបុគ្គលសម្រាប់នាំចូលទំនិញពាក់ម៉ាកផ្តាច់មុខមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- "ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ" គឺជាការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខដោយក្រសួងពាណិជ្ជកម្ម ផ្អែកតាមការស្នើសុំរបស់នីតិបុគ្គលដែលបានទទួលសិទ្ធិផ្តាច់មុខពីម្ចាស់ម៉ាក។

**ប្រការ ៥.- វាក្យសព្ទ**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- **"លិខិតប្រគល់សិទ្ធិផ្តាច់មុខ"** សំដៅដល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខចេញដោយម្ចាស់ម៉ាកជូនទៅអ្នកទទួលសិទ្ធិ ដែលមានបញ្ជាក់ច្បាស់លាស់អំពី ម៉ាក ជំពូក និងប្រភេទនៃទំនិញ។

២- **"លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ"** សំដៅដល់លិខិតទទួលស្គាល់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជាដែលចេញដោយក្រសួងពាណិជ្ជកម្ម។

៣- **"ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក"** សំដៅដល់ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកសម្រាប់នាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ក្រោយពីទទួលបានពីការចុះបញ្ជីម៉ាករួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំដោយម្ចាស់ម៉ាកខ្លួនឯង ។

**ប្រការ ៦.- ទំនិញដែលមិនអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ**

ទំនិញដែលមិនអនុញ្ញាតឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខមានដូចខាងក្រោម៖

១- ទំនិញដែលបានប្រើរួចគ្រប់ប្រភេទ
២- ផលិតផលឱសថ
៣- មុខទំនិញហាមឃាត់ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៧.- ទំនិញជាប់កម្រិតកំណត់**

ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន ។

**ប្រការ ៨.- ការកម្រិតសិទ្ធិដែលទទួលបានពីការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ**

១- ម្ចាស់ម៉ាកដែលទទួលបានលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬអ្នកដែលទទួលបានលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា មិនមានសិទ្ធិហាមឃាត់លើការនាំចូលនូវមុខទំនិញដូចខាងក្រោម៖

ក- ទំនិញដែលនាំចូលយកមកប្រើប្រាស់ដោយព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

ខ- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅមិនធ្វើពាណិជ្ជកម្មនិងសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ និងទំនិញប្រើរួចគ្រប់ប្រភេទ។

២- បុគ្គល អង្គការ អង្គទូត និងក្រសួង ស្ថាប័ន ដែលមានបំណងនាំចូលទំនិញដូចមានចែងក្នុងប្រការ៨(១) ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ដោយមានភ្ជាប់មកជាមួយនូវឯកសារយោងដូចខាងក្រោមៈ

ក- លិខិតអនុញ្ញាតពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំពោះអង្គទូត និងអង្គការអន្តរជាតិ ឬលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃចំពោះអង្គការ ឬសហគមន៍ក្នុងស្រុក ឬលិខិតអនុញ្ញាតពីក្រសួងអាណាព្យាបាល ដែលមានបញ្ជាក់ពីបរិមាណ និងម៉ូដែល ព្រមទាំងគោលបំណងយកមកប្រើប្រាស់ ។

ខ- មុននឹងធ្វើការនាំចូលត្រូវមានកិច្ចសន្យាទិញ លក់ និង/ឬ វិក្កយបត្រប្រូហ្វ័រម៉ា (Pro-forma) ឬឯកសារពាណិជ្ជកម្មដែលមានតម្លៃប្រហាក់ប្រហែល ។

គ- ក្រោយការនាំចូលត្រូវផ្តល់នូវវិក្កយបត្រទិញ លក់ និង/ឬ តារាងបញ្ជាក់អំពីបញ្ជីវេចខ្ចប់ (Packing list) និង/ឬ អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading) និងប្រតិវេទន៍គយ (Customs Declaration) ។

៣- បន្ទាប់ពីចេញលិខិតអនុញ្ញាតនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដែលទទួលបានការលើកលែងក្នុងប្រការ៨ដោយលើកលែងចំណុច៤នៃប្រការនេះ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅរដ្ឋបាលគយនិងរដ្ឋាករនិងអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងជូនដំណឹងទៅអ្នកដែលបានទទួលសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដើម្បីជួយសម្រួលដល់ការនាំចូល។

៤- មិនតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតនាំចូលឡើយ ចំពោះទំនិញនិងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលគ្មានលក្ខណៈពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ៩.- សិទ្ធិដែលទទួលបានពីការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

១- សិទ្ធិនាំចូលនិងចែកចាយទំនិញពាក់ម៉ាកផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់តាមរយៈការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

២- អ្នកទទួលសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ មានសិទ្ធិប្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ចំពោះបុគ្គលណាដែលបាននាំចូលនិងចែកចាយទំនិញស្របគ្នាដោយបំពាននូវសិទ្ធិរបស់ខ្លួន ដើម្បីរកដំណោះស្រាយដូចមានចែងក្នុងប្រការ១៨ នៃប្រកាសនេះ ។

៣- សិទ្ធិនាំចូលនិងចែកចាយទំនិញពាក់ម៉ាកផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផុតរលត់វិញ នៅពេលដែលទំនិញពាក់ម៉ាកផ្តាច់មុខនីមួយៗនោះ ត្រូវបានលក់និងទូទាត់រួចរាល់លើកដំបូងនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១០.- បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិផ្តាច់មុខលើម៉ាក

១- សិទ្ធិផ្តាច់មុខលើម៉ាក

ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវយកម៉ាករបស់ខ្លួនមកធ្វើការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមមាត្រា៣ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ សិទ្ធិប្រើប្រាស់ម៉ាករួមមាន ការផលិត ការផ្សព្វផ្សាយ ការលក់ ការនាំចេញ ការនាំចូលជាដើម ដូចមានកំណត់ក្នុងមាត្រា១១ ២៤ និង ៦៦ នៃច្បាប់ខាងលើ។ សិទ្ធិផ្តាច់មុខដែលទទួលបានពីការចុះបញ្ជី អាចផ្ទេរទៅភាគីណាមួយ ដោយមានការយល់ព្រមពីម្ចាស់ម៉ាក និងធ្វើការកត់ត្រានិងតម្កល់នៅក្រសួងពាណិជ្ជកម្ម។

២- គោលការណ៍ផុតរលត់សិទ្ធិ (Exhaustion of Rights)

ក- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មិនត្រូវបានរាប់បញ្ចូលការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ម៉ាក ឬដោយបុគ្គលដែលមានការយល់ព្រមពីម្ចាស់ម៉ាកនោះឡើយ ដូចបានកំណត់ក្នុងមាត្រា១១(គ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលកម្ពុជាបានកំណត់យកគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ (National Exhaustion of Rights)។

ខ- ផ្អែកតាមគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬអ្នកទទួលសិទ្ធិដែលបានកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខមានសិទ្ធិប្តឹងរារាំងការនាំចូលស្របគ្នា (Parallel Importation) នូវទំនិញពាក់ម៉ាកដូចគ្នា ដោយភាគីទីបី។

## ប្រការ ១១.- នីតិវិធីកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

បុគ្គលដែលស្នើសុំការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមនីតិវិធីដូចខាងក្រោម៖

១- លក្ខខណ្ឌ

ក. បុគ្គលដែលអាចទទួលបាននូវការប្រគល់សិទ្ធិផ្តាច់មុខ ត្រូវមានទ្រង់ទ្រាយជានីតិបុគ្គល (អ្នកទទួលសិទ្ធិ) ។

ខ. ការប្រគល់សិទ្ធិផ្តាច់មុខត្រូវធ្វើឡើងតាមការព្រមព្រៀង រវាងអ្នកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយភាគីអ្នកប្រគល់សិទ្ធិ និងត្រូវបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខាក្នុងនាមអ្នកប្រគល់សិទ្ធិដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស ឬក្រសួងយុត្តិធម៌ ។

គ. ក្នុងករណីដែលម្ចាស់ម៉ាកមិនបានប្រគល់សិទ្ធិផ្តាច់មុខដោយផ្ទាល់ទៅអ្នកទទួលសិទ្ធិក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកទទួលសិទ្ធិដែលចង់ប្រគល់សិទ្ធិបន្ត ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម ដែលមានចែងអំពីសិទ្ធិប្រគល់សិទ្ធិបន្តទៀត។

ឃ. អ្នកទទួលសិទ្ធិ អាចដាក់ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៣(បី)ខែយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិ ។

ង. ការដាក់ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវបង់កម្រៃសេវាសាធារណៈទៅតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ ។

ច. ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ អាចធ្វើទៅបានលុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅអ្នកស្នើសុំ ក្នុងករណីដែលមិនអាចធ្វើការកត់ត្រាបាន ឬតម្រូវឲ្យបំពេញឯកសារបន្ថែម ។

ឆ. ទំនិញពាក់ម៉ាកផ្តាច់មុខដែលបានកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅក្រសួងពាណិជ្ជកម្មរួចហើយ មិនអាចអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់ជូនបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែការប្រគល់សិទ្ធិផ្តាច់មុខនោះ ត្រូវបានដកហូត ឬផុតសុពលភាព។

ជ. ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ លើទំនិញតែមួយនិងពាក់ម៉ាកដូចគ្នាក៏ប៉ុន្តែមានយថាប្រភេទខុសគ្នា អាចអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន លុះត្រាតែមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម។

ឈ.ការប្រគល់សិទ្ធិផ្តាច់មុខ នឹងគ្មានអានុភាពចំពោះអ្នកទទួលសិទ្ធិ និងភាគីទីបីឡើយ ប្រសិនបើលិខិតប្រគល់សិទ្ធិផ្តាច់មុខមិនបានយកមកធ្វើការកត់ត្រានិងតម្កល់ឲ្យបានត្រឹមត្រូវតាមប្រកាសនេះ ។

២- ឯកសារតម្រូវ

ក. ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវប្រើប្រាស់លិខិតផ្លូវការរបស់ក្រុមហ៊ុន និងត្រូវចុះហត្ថលេខា និងប្រថាប់ត្រាដោយអ្នកទទួលសិទ្ធិក្នុងស្រុក ឬម្ចាស់ម៉ាក។

ខ. លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពី៖

១. ឈ្មោះអ្នកប្រគល់សិទ្ធិ ឬ/និងអ្នកប្រគល់សិទ្ធិបន្ត និងអាសយដ្ឋានត្រឹមត្រូវតាមវិញ្ញាបនបត្រចុះបញ្ជីម៉ាក

២. ឈ្មោះនីតិបុគ្គលនិងទីស្នាក់ការក្រុមហ៊ុននៃអ្នកទទួលសិទ្ធិ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

៣. កម្មវត្ថុនៃការប្រគល់សិទ្ធិផ្តាច់មុខត្រូវបញ្ជាក់អំពី ម៉ាក លេខចុះបញ្ជី ជំពូក និងប្រភេទនៃទំនិញ

៤. ប្រទេស ឬដែនដីគ្របដណ្តប់ដោយសិទ្ធិដែលបានប្រគល់

៥. កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តនៃលិខិតប្រគល់សិទ្ធិ

៦. សុពលភាពដោយមិនឲ្យលើសពីរយៈពេល១០ឆ្នាំ

៧. ឈ្មោះ និងហត្ថលេខារបស់អ្នកប្រគល់សិទ្ធិ ព្រមទាំងកាលបរិច្ឆេទ ។

គ. ឯកសារភ្ជាប់មកជាមួយនឹងពាក្យស្នើសុំ៖

១. ច្បាប់ដើមនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ចំនួន០១ច្បាប់ ។

២. លិខិតអនុញ្ញាតឲ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលចំពោះមុខទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន ។

៣. ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកចំនួន ០១ច្បាប់ ។

៤. ច្បាប់ចម្លងនៃលក្ខន្តិកៈក្រុមហ៊ុន គោលការណ៍ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន០១ច្បាប់ ។

៥. ច្បាប់ចម្លងនៃប័ណ្ណប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់នីតិបុគ្គលចំនួន០១ច្បាប់ ។

៦. វិក្កយបត្របង់ប្រាក់កម្រៃសេវាសាធារណៈ ។

## ប្រការ ១២.- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក

១. តាមការស្នើសុំដោយស្ម័គ្រចិត្តពីម្ចាស់ម៉ាក ក្រសួងពាណិជ្ជកម្មអាចធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក សម្រាប់សម្រួលដល់ការនាំចូលនិងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ការស្នើសុំលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ម្ចាស់ម៉ាកត្រូវបំពេញតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ៣ ប្រការ៥ចំណុច៣ ប្រការ៦ និង/ឬ ប្រការ៧ ប្រការ៨ និងប្រការ១១ ចំណុច១(ង) ចំណុច២(ក) និងចំណុច២(គ) ដោយលើកលែងចំណុច២(គ)(១) នៃប្រការនេះ។

## ប្រការ ១៣.- សុពលភាព ភារកិច្ច និងសិទ្ធិ

១- សុពលភាព

ក- លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា មានសុពលភាព២(ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ខ- សុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា អាចមានរយៈពេលខ្លីជាង២(ពីរ)ឆ្នាំ ដោយផ្អែកតាមសុពលភាពអប្បបរមារបស់លិខិតណាមួយនៃ លិខិតប្រគល់សិទ្ធិផ្ដាច់មុខ វិញ្ញាបនបត្រចុះបញ្ជីម៉ាក និងលិខិតអនុញ្ញាតឲ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬរាជរដ្ឋាភិបាល។

២- កាតព្វកិច្ច

ក- ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ ត្រូវបោះពុម្ពផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់ផ្ដាច់មុខ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន៣(បី)លេខជាប់ៗគ្នា ។ ក្នុងករណីចាំបាច់ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ អាចបញ្ជូនច្បាប់ចម្លងនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខទៅអ្នកនាំចូលដោយផ្ទាល់ ដើម្បីអ្នកនាំចូលបានជ្រាបជាព័ត៌មាន ។

ខ- នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខនោះ ក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និង/ឬ ក្នុងគេហទំព័រ www.cambodiaip.gov.kh ។

គ- អ្នកនាំចូលទំនិញតែមួយ ពាក់ម៉ាកដូចគ្នាទៅនឹងទំនិញដែលមានលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខរួចហើយ ត្រូវបញ្ចប់ប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន រួមទាំងទំនិញដែលស្តុកទុកក្នុងឃ្លាំងក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។

៣- សិទ្ធិ

ចាប់ពីរយៈពេល៩០(កៅសិប)ថ្ងៃ ដូចបានកំណត់ក្នុងប្រការ១៣ចំណុច២(គ)ខាងលើ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្ដឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីចាត់វិធានការតាមបញ្ញត្តិច្បាប់ជាធរមាន ចំពោះទំនិញតែមួយពាក់ម៉ាកដូចគ្នា ។

**ប្រការ ១៤.- ការបាត់បង់សុពលភាពជាស្វ័យប្រវត្តិ**

សុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ ត្រូវបាត់បង់ជាស្វ័យប្រវត្តិ ប្រសិនបើៈ

ក- ការប្រគល់សិទ្ធិផ្ដាច់មុខត្រូវបានដកហូតវិញ ឬ

ខ- សុពលភាពនៃការចុះបញ្ជីម៉ាកត្រូវបាត់បង់ដោយប្រការណាមួយ ឬ

គ- ការចុះបញ្ជីម៉ាកដែលបានចុះបញ្ជីរួចហើយត្រូវបានប្ដូរម្ចាស់កម្មសិទ្ធិ ឬ

ឃ- ការនាំចូលទំនិញជាប់កម្រិតកំណត់ដែលបានអនុញ្ញាត ត្រូវបាននាំចូលគ្រប់ចំនួនរួចហើយ ឬ

ង- ការអនុញ្ញាតឲ្យនាំចូលទំនិញជាប់កម្រិតកំណត់ ត្រូវបានដកហូតវិញ ។

## ប្រការ ១៥.- មោឃភាពនៃការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

១- លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ បានចេញដោយក្រសួងពាណិជ្ជកម្មកន្លងមកដែលមិនបានកំណត់សុពលភាព ត្រូវចាត់ទុកជានិរាករណ៍ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ។

២- ជនណាដែលមានការពាក់ព័ន្ធអាចស្នើសុំក្រសួងពាណិជ្ជកម្ម ឲ្យផ្តល់មោឃភាពលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខបាន។

៣- ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើមោឃភាពលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ក្នុងករណីបុគ្គលដែលស្នើសុំនោះបង្ហាញថា៖

ក- លិខិតបញ្ជាក់ ឬលិខិតកត់ត្រានិងតម្កល់ មិនបានបំពេញលក្ខខណ្ឌតម្រូវនៃប្រការណាមួយនៃប្រកាសនេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬ

ខ- លិខិតប្រគល់សិទ្ធិផ្តាច់មុខមានភាពមិនប្រក្រតីដោយប្រការណាមួយ។

៤- ក្រសួងពាណិជ្ជកម្ម មានសិទ្ធិលុបការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬការកត់ត្រានិងតម្កល់លិខិតប្រគល់ផ្តាច់មុខប្រសិនបើ៖

ក- បុគ្គលណាដែលអនុវត្តផ្ទុយនឹងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬ

ខ- មានការស្នើសុំពីម្ចាស់ម៉ាក ឬពីអ្នកទទួលសិទ្ធិដោយភ្ជាប់មកជាមួយនូវឯកសារយោងគ្រប់គ្រាន់ ។

៥. ពាក្យស្នើសុំធ្វើមោឃភាពចំពោះលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវបង់ប្រាក់កម្រៃសេវាសាធារណៈដោយអ្នកដាក់ពាក្យស្នើសុំតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ ។

៦- ការធ្វើមោឃភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវមានអានុភាពអនុវត្តចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច។

## ប្រការ១៦.- ការបន្តសុពលភាព

១- បុគ្គលដែលមានគោលបំណងបន្តសុពលភាពនៃ លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវដាក់ពាក្យស្នើសុំឲ្យបាន៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព ហើយត្រូវបំពេញតាមនីតិវិធីនិងលក្ខខណ្ឌ ដូចខាងក្រោម៖

ក- អ្នកដាក់ពាក្យស្នើសុំ ត្រូវបង់ប្រាក់កម្រៃសេវាសាធារណៈដូចបានកំណត់ក្នុងប្រកាសជាធរមាន ។

ខ- ច្បាប់ចម្លងនៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខ ដែលបានតម្កល់នៅក្រសួងពាណិជ្ជកម្ម នៅមានសុពលភាពនៅឡើយ ។ ក្នុងករណីលិខិតប្រគល់សិទ្ធិផ្ដាច់មុខបានផុតសុពលភាព អ្នកស្នើសុំត្រូវដាក់លិខិតប្រគល់សិទ្ធិផ្ដាច់មុខថ្មី។

គ- ត្រូវបំពេញលក្ខខណ្ឌ នីតិវិធី និងឯកសារតម្រូវដូចមាននៅពេលដាក់ពាក្យស្នើសុំដំបូង ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ ។

២- ក្នុងករណី លិខិតប្រគល់សិទ្ធិផ្ដាច់មុខ និងវិញ្ញាបនបត្រចុះបញ្ជីម៉ាក ព្រមទាំងលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន នៅមានសុពលភាពចាប់ពី ២(ពីរ)ឆ្នាំឡើងទៅ ការបន្តសុពលភាពត្រូវមានរយៈពេល២(ពីរ)ឆ្នាំ ។ ក្នុងករណីលិខិតប្រគល់សិទ្ធិ និងវិញ្ញាបនបត្រចុះបញ្ជីម៉ាក ព្រមទាំងលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន មានសុពលភាពតិចជាង២(ពីរ)ឆ្នាំ ការបន្តសុពលភាពត្រូវមានរយៈពេលស្មើនឹងសុពលភាពអប្បបរមានៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខ ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ឬលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន ។

៣- លិខិតបន្តសុពលភាពមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃផុតសុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ ហើយត្រូវបោះពុម្ពផ្សាយ ដូចមានចែងក្នុងប្រការ១៣ ចំណុច២(ក) និង (ខ) នៃប្រកាសនេះ។

**ប្រការ ១៧.-សិទ្ធិនិងរយៈពេលនៃបណ្ដឹងតវ៉ា**

១- ជនណាដែលមានការពាក់ព័ន្ធមានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាបណ្ដឹងតវ៉ា ឬតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងការបញ្ជាក់ ឬការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខរបស់ក្រសួងពាណិជ្ជកម្ម ។

២- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាបណ្ដឹងតវ៉ាជាកម្មវត្ថុនៃបណ្ដឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេច។

**ប្រការ ១៨.- ការបំពានសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខ និងនីតិវិធីដោះស្រាយវិវាទ**

ការបំពានសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខត្រូវដោះស្រាយតាមនីតិវិធី ដូចខាងក្រោម៖

១- អ្នកទទួលសិទ្ធិស្របច្បាប់ អាចចេញលិខិតព្រមានដល់អ្នកនាំចូលទំនិញស្របគ្នាឲ្យបញ្ឈប់ការនាំចូលដែលបំពានទៅលើសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខរបស់ខ្លួន ។

២- តាមការស្នើសុំអន្តរាគមន៍ពីអ្នកទទួលសិទ្ធិស្របច្បាប់ ក្រសួងពាណិជ្ជកម្មអាចចេញលិខិតព្រមានដល់អ្នកនាំចូលទំនិញស្របគ្នា ឲ្យបញ្ឈប់ការនាំចូលដែលបំពានទៅលើសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខ។

៣- អ្នកទទួលសិទ្ធិស្របច្បាប់ និងអ្នកនាំចូលទំនិញស្របគ្នាអាចធ្វើការសម្រុះសម្រួលអំពីផលប៉ះពាល់ និងការខូចខាតអំពីការនាំចូលទំនិញស្របគ្នាដោយៈ

- អនុញ្ញាតឲ្យអ្នកនាំចូលស្របគ្នាបន្តលក់ទំនិញ ដែលរំលោភសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខតាមរយៈសងការខូចខាតជូនអ្នកទទួលសិទ្ធិស្របច្បាប់ក្នុងតម្លៃឯកភាពគ្នា ឬ
- អ្នកទទួលសិទ្ធិស្របច្បាប់ទទួលទិញទំនិញដែលនាំចូលស្របគ្នាតាមតម្លៃស្រុះស្រួល។

៤- ក្នុងករណីគ្មានការឯកភាពគ្នាតាមជម្រើសខាងលើ ទំនិញដែលនាំចូលនោះត្រូវបញ្ជូនត្រឡប់ទៅប្រភពដើមវិញ ។

៥- ភាគីវិវាទត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលសម្រុះសម្រួល ដោយចុះហត្ថលេខា ឬផ្តិតមេដៃចំពោះមុខ និងមានការចុះហត្ថលេខាដឹងឮ ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ជូនមួយច្បាប់មកក្រសួងពាណិជ្ជកម្ម។

៦- កំណត់ហេតុស្តីពីលទ្ធផលសម្រុះសម្រួលអាចប្រើប្រាស់ជាឯកសារយោងអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

៧- ក្នុងករណីគ្មានការឯកភាពលើការសម្រុះសម្រួលណាមួយ ភាគីវិវាទអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

**ប្រការ ១៩.- ភាពអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

<u>ចម្លងជូនៈ</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានគាំពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។